**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៤ អនក្រ.បក.

# អនុក្រឹត្យ
## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ
## របស់ក្រសួងទេសចរណ៍

*****

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស /៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១០៩៤ / ៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១០៩៤ / ៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស / រកម / ០១៩៦ / ១៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ/ បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍
- តាមការអនុម័តរបស់គណៈរដ្ឋមន្ត្រីថ្ងៃទី ៧ ឧសភា ឆ្នាំ ១៩៩៧

# សម្រេច ៖

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.- អនុក្រឹត្យនេះរៀបចំបណ្តាអង្គភាពនៃក្រសួងទេសចរណ៍ និងកំណត់បេសកកម្ម របស់ក្រសួង និងមុខការនៃអគ្គនាយកដ្ឋាននិងនាយកដ្ឋាននានា ។

## ជំពូក ២

## បេសកកម្ម និងរចនាសម្ព័ន្ធ

មាត្រា ២.- ក្រសួងទេសចរណ៍ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មអោយដឹកនាំ និងគ្រប់គ្រងវិស័យទេសចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣.- ក្រសួងទេសចរណ៍មានមុខងារនិងភារកិច្ចដូចតទៅ ៖

- កំណត់នយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ និងរៀបចំផែនការអភិវឌ្ឍន៍វិស័យទេសចរណ៍
- ជំរុញលើកទឹកចិត្តការងារវិនិយោគទុន ក្នុងវិស័យទេសចរណ៍ ដោយយោងលើការអភិវឌ្ឍជាយុទ្ធសាស្ត្ររបស់ជាតិ
- រៀបចំគ្រប់គ្រងវិស័យឧស្សាហកម្មទេសចរណ៍
- តំរង់ទិសនិងត្រួតពិនិត្យរាល់សេវា ដែលបំរើអោយវិស័យទេសចរណ៍
- កំណត់រៀបចំតំរង់ទិស ត្រួតពិនិត្យ និងថែរក្សារមណីយដ្ឋានធម្មជាតិ រមណីយដ្ឋានកែច្នៃទេសចរណ៍នានា មណ្ឌលទេសចរណ៍ តំបន់អភិវឌ្ឍន៍ទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា
- សិក្សាសំណើសុំបង្កើត ទទួលស្គាល់និងត្រួតពិនិត្យសាលាឯកជន និងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ បំរើអោយវិស័យទេសចរណ៍
- ធ្វើការផ្សព្វផ្សាយវិស័យទេសចរណ៍ ក្នុងនិងក្រៅប្រទេស
- ចាត់តំណាងនៅក្រៅប្រទេសដោយសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ចុះហត្ថលេខាលើកិច្ចសន្យាអនុវត្តនានា ដែលទាក់ទងទៅលើវិស័យទេសចរណ៍ក្រោយពីបានគោលការណ៍ពីរាជរដ្ឋាភិបាល
- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មដល់ក្រុមហ៊ុនទេសចរណ៍ ទីភ្នាក់ងារទេសចរណ៍ និងមគ្គុទ្ទេសក៍ទេសចរណ៍
- ត្រួតពិនិត្យលើសេវាទេសចរណ៍និងអាជីវកម្មផ្សេងៗទៀតដែលទាក់ទងនិងវិស័យទេសចរណ៍
- ធ្វើអធិការកិច្ចវិស័យទេសចរណ៍ ។

មាត្រា ៤.- ក្រសួងទេសចរណ៍មានរចនាសម្ព័ន្ធ ដូចតទៅ :

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អធិការដ្ឋាន
- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានទេសចរណ៍
- អង្គភាពមូលដ្ឋាន ។

អង្គការលេខរបស់ក្រសួងទេសចរណ៍ ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

## ជំពូក ៣

## ខុទ្ទកាល័យរដ្ឋមន្ត្រី

មាត្រា ៥.- ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទបញ្ញត្តិនៃអនុក្រឹត្យ លេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង នឹងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូក ៤

## អធិការដ្ឋាន

មាត្រា ៦.- អធិការដ្ឋានរបស់ក្រសួងទេសចរណ៍ ទទួលបន្ទុក :

- ធ្វើអធិការកិច្ចជាប្រចាំ ទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តិទៅរបស់អង្គភាព ដែលបានធ្វើអធិការកិច្ចហើយនោះ និងពីមធ្យោបាយកែលំអការប្រព្រឹត្តិទៅ របស់អង្គភាពទាំងនោះ
- ប្រតិបត្តិភារៈកិច្ចតាមការដែលរដ្ឋមន្ត្រីបានប្រគល់ទុកចិត្ត ។

អធិការដ្ឋានដឹកនាំដោយអធិការមួយនាក់អាច អមដោយអធិការរងមួយរូប ឬ ច្រើនរូបជួយធ្វើការ ទៅតាមការចាំបាច់ ។

## ជំពូក ៥

## នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

មាត្រា ៧.- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុទទួលបន្ទុក :

ក. ក្នុងវិស័យរដ្ឋបាល

- សំរបសំរួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និង រវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទ
- គ្រប់គ្រងនិងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង
- សរុបនិងធ្វើរបាយការណ៍ការងារនិងសកម្មភាពផ្សេងៗរបស់ក្រសួង ។